តើអ្នកជឿលើរឿងអបិយជំនឿ មន្តអាគម ខ្មោចព្រាយបិសាចដែរឬទេ? បើជឿ តើជឿកម្រិតណាដែរ? ចុះអ្នកធ្លាប់ដឹងឮអ្វីខ្លះទាក់ទងនឹងរឿងអស់នេះ?

និទានពេជ្របណ្ឌិតមួយថ្មីនេះ បរិយាយអំពីចាងហ្វាងម្នាក់ឈ្មោះ ខ្លឹម ហែម និងអពមង្គលធំមួយដែលគ្រួសារគាត់បានជួបនាសម័យកាលក្រោមអាណានិគមបារាំង....។ នេះជាតំណាលឡើងវិញរបស់លោកតា មៀក ចាក។

---

ដោយសារទេសាភិបាលឥណ្ឌូចិនសញ្ជាតិបារាំង មានបំណងចង់ផ្តួលរំលំរាជវង្សនិងព្រះមហាក្សត្រខ្មែរព្រមទាំងមហិច្ឆតាធ្វើការគ្រប់គ្រងពេញទីលើកម្ពុជាលូកដៃជ្រៀននូវការកិច្ចនៃព្រះបរមរាជវាំងនៅភ្នំពេញ ដូច្នេះ ទសវត្សដំបូងៗនៃការគ្រប់គ្រងរបស់ខ្លួន បារាំងបានធ្វើកំណែទម្រង់ កាត់បន្ថយអំណាចរបស់ព្រះមហាក្សត្រ នាម៉ឺន និង លុបចោលទាសភាព។

ការបះបោរ ភាពចលាចល ព័ត៌មានបំភាន់ នៃការផ្លាស់ប្តូរនយោបាយ ក្នុងចំណោមរាជវង្សានុវង្ស មន្ត្រី នាម៉ឺន បានសង្កត់បន្ថែមទៅលើស្ថានការណ៍អាសន្នទូទាំងប្រទេស...។ ឪពុកធំ(អ៊ុំខាងឪពុក)របស់ជីតាខ្ញុំបានស្លាប់ក្នុងដំណើរវិលត្រលប់មកស្រុកកំណើតដោយសារជំងឺ តែនៅតាមផ្លូវគាត់បានប្រគល់ជីតាខ្ញុំឈ្មោះ គុម ឱ្យទៅតាមនិងរស់នៅក្រោមការគ្រប់គ្រងនៃចាងហ្វាងមួយរូបដែលជាអ្នកបោះពុម្ពផ្សាយ និងមានមុខងារសរសេរបទប្រកាសសាធារណៈផ្សេងៗ។

កាលណោះលោកតាខ្ញុំ មានវ័យប្រមាណជា៧ឆ្នាំ ចំណែកលោកចាងហ្វាងខ្លឹម ហែមគាត់មានវ័យប្រហែលជា៣០រៀបការភរិយានិងបានកូនស្រីពីរនាក់។ រឿងរ៉ាវនៃសីមាអំបោះលឿងនេះ លោកតាខ្ញុំបានរៀបរាល់ប្រាប់ចៅៗ ដែលកាលអំឡុងឆ្នាំ១៩៥០ប្លាយ ដែលខ្ញុំទើបតែអាយុបានប្រហែល ១២ឆ្នាំ ។ លោកតាបានតំណាលថា....

កំពង់ធំឆ្នាំ១៨៦៨.....

រទេះគោបរទៅមុខឃឹតៗ ស្របពេលដែលព្រះអាទិត្យនៅតែភ្លឺរពីលើជួរភ្នំភាគខាងលិចនៃដំណើររបស់យើងប៉ុន្តែគ្មានកម្តៅ គ្មានបន្តិចទេញើស ។

សំណាងដែលបាននៅលើរទេះ ម៉្លេះសមតុមភ័យយ៉ាងនឹងអាកាសដែលស្រាប់តែចុះត្រជាក់ខ្យល់បក់រ៉ូវៗចម្លែក។

ដីហុយទ្រលោម រហូតដល់ពេលខ្លះគោក៏ចង់តែឈប់ដើងព្រោះខ្ជិល។ បើកុំតែអ្នកបររទេះរបស់លោកចាងហ្វាងស្រែកបង្អើលវា វាហាក់មិនព្រមចង់ស្ទុះទៅមុខសោះ.....

ផ្លូវមិនស្វាត់ទេ។ ជនានុជន ខ្លះដើរបញ្ច្រាសទិសនឹងរទេះរបស់យើង ចូលទៅកាន់បណ្តាភូមិករៀងអ ភាគច្រើនប្រឡាក់ប្រលូសហត់នឿយ ព្រោះបានត្រលប់មកពីដំណើរដ៏សែនវែងឆ្ងាយ

អ្នកខ្លះមកជាក្រុម ដែលមានខោអាវបំណះតាមបែបធ្លាប់ត្រូវលក់ខ្លួនទៅធ្វើការនៅតាមផ្ទះមន្ត្រីធំនាម៉ឺនគហបតី បានទទួលសេរីភាពវិលមកវិញទាំងមិនដឹងផងថា ភូមិកំណើតរបស់ខ្លួនមានរូបភាពបែបម៉េច ហើយជីដូនជីតាក៏នៅរស់នៅវាននៅឡើយឬយ៉ាងណា។

អ្នកខ្លះស្លៀកក្បិន អ្នកខ្លះស្លៀកសម្លុយ ចំណែកលោកចាងហ្វាងនៅលើរទេះនេះ ពិតជាមានសម្លៀកបំពាក់ភាពថ្លៃថ្នូរ ដោយសំពត់ក្បិន និងពាក់អៀងសូត្រក្រាស់។ គាត់ទុកពុកមាត់វែងគ្របបាំងបបូរមាត់ ប៉ុន្តែតាមពិតទៅក្រោយមកតុមបានដឹងថា គាត់មានវ័យប្រមាណជាសាមសិបឆ្នាំតែប៉ុណ្ណោះ ។

«ឯងសប្បាយចិត្តទេអាតុម? បន្តិចទៀតអាលហ្នឹងទៅដល់ផ្ទះធំ របស់របរម្ហូបឆ្ងាញ់ៗត្រៀបត្រា! តែឯងត្រូវតែតាំងស្មារតីខំរៀនសាស្ត្រា រៀនភាសាជាតិមិនឱ្យខ្ជិល ! »

តុមឱនក្បាល តាមរបៀបក្មេងដែលត្រូវបានរើសមក។ គេត្រេចចរតាមលោកឪពុកធំ ធ្វើជាអ្នកជួញដូររបស់របរអាំងឆ្អើរនៅតាមបណ្តោយបឹងទន្លេសាប ។ យោងតាមសភាពទុរគតនិងកំព្រាឪពុកម្តាយ តុមមានតែឪពុកធំដែលជាអ៊ំប្រុសខាងឪពុក ថែរក្សាបីបាច់បង្រៀនអក្សរលេខនព្វន្តខ្លះៗ ប៉ុន្តែមិនសូវពូកែសំដី។ ទោះយ៉ាងណាក្មេងនេះ មានការចងចាំល្អនិងពូកែល្អិតល្អន់និយមកត់ចំណាំអ្វីៗដែលបានកើតឡើងជុំវិញខ្លួន។

ដោយអ៊ុំប្រុសបានគ្រុនក្តៅសន្ធំ និងស្លាប់យ៉ាងទាន់ហន់នៅតាមផ្លូវ គាត់បានប្រគល់ក្មួយកំព្រាមកឱ្យជ្រកកោននឹងលោកចាងហ្វាងម្នាក់នេះ មានឈ្មោះថា ខ្លឹម ហែម ដែលជួបគ្នាចៃដន្យនៅក្នុងដំណើរត្រលប់ពីភ្នំពេញមកស្រុកកំណើត។

ចាងហ្វាងបានសន្យានឹងឪពុកធំរបស់តុបថានឹងថៃទាំក្មេងនេះឱ្យបានល្អ។

រទេះគោបត់ចូលច្រកផ្លូវតូចមួយ....មេឃព្រលប់ហើយ នៅទីនោះ គេបានឃើញផ្ទះសម័យធ្វើពីថ្មរចនាបទបារាំងមួយសែនទំនើប។

«យើងបានជាន់ផ្ទះថ្មពិតហើយ!»

តុមគិតរីករាយជាខ្លាំង។

ផ្ទះដ៏ឡិតមានត្រឹម១ជាន់រាបផ្ទាល់ដី តែវាតធំស្ដឹមស្ដៃ និងរឹងមាំណាស់ បើធៀបនឹងសំណង់មន្ត្រីនៅភូមិផ្សេងៗដែលតុមធ្លាប់ត្រាច់ចរឆ្លងកាត់មកឃើញ។

«ពុក!ពុក!»

ក្មេងពីរនាក់រត់មកដោយរីករាយធ្វើឱ្យតុមចំហមាត់សម្លឹងពួកគេទាំងដឹងជាមុនហើយថាជាកូនស្រីទាំងពីររបស់ចាងហ្វាង។

នៅក្នុងសំលៀកបំពាក់សំពត់ប៉ោង ដែលជាវប្បធម៌ឆ្លងពីប្រទេសបារាំង កូនស្រីទាំងពីររបស់លោកចាងហ្វាង ម្នាក់ ឈ្មោះថា បុប្ផារ័ត្ន ជាកូនបងមានអាយុប្រហែលជាប្រាំបួនឆ្នាំ ប៉ុន្តែមាឌតូចល្អិតចំណែកប្អូនតូចរបស់កុលារ័ត្ន មានអាយុប្រហែលជាបួនទៅប្រាំឆ្នាំជា ក្មេងស្រែកបានឮៗនិងនិយាយច្រើនមិនឈប់ មានសំឡេងស្រួយស្រើប។

តាមពិត គេហដ្ឋាននេះមានដាំផ្កាកុលាបជាច្រើនជួរជុំវិញ។ តុមសម្គាល់មើលនៅពេលដែលបុរសអ្នកបរទេះឈ្មោះអុល បំបោលគោចូលក្រោលហើយដើរ ទៅដងទឹកមកស្រោចផ្កាទាំងជួរយ៉ាងយកចិត្តទុកដាក់ជាខ្លាំង។

ប្រាកដណាស់ម្ចាស់គេហដ្ឋានជាមនុស្សស្រីតែងស្រលាញ់ផ្កា។ អ្នកអន្ទី គឺជាភរិយាដ៏ស្រស់ស្អាតម្នាក់ មានសម្បុរលឿង សក់វែង សឹងដល់ គន្លាក់ជើងខាងក្រោម ប៉ុន្តែគាត់មិនទម្លាក់នោះទេ បានបួងយ៉ាងសមសួន មើលទៅដូចជាធ្ងន់ខ្លាំងនៅគល់កខាងក្រោយរបស់គាត់។

ទឹកមុខរបស់អ្នកអន្ទីនេះញញឹមជានិច្ច គាត់មានរោមភ្នែកវែងៗ តុមតាមមើលលង់ភ្លឹកពេកគាត់ស្រូតចេញមកទទួលស្វាមី។

អ្នកនេះស្លៀកខៀនពណ៌លឿងស្រគាំនិងចោមពុម្ពដោយផាឌឹបបៃតង។ សក់មានសៀតផ្កាចំប៉ីពីរបើចោលក្លិនក្រអូបសាយ។

« ខ្ញុំខំស្រូតមកដោយសារឮសូរអ្នកឈើ!»

ស្ត្រីនេះញញឹមរមទម្យពេលឮប្តីស្រលាញ់ឈើថ្កាល ។ តុមមិនទាន់បានឮគាត់ឆ្លើយនឹងប្តីថានៅឈើមែនឬជា ក៏ចាងហ្វាងយកខ្សៀរចង្អុលមកច្រមុះតុមហើយបង្គាប់បន្ថែមទៅរកភរិយាៈ

«ហេតុក្មេងនេះកំព្រាតែឯងនៅតាមផ្លូវ ឪពុកធំរបស់វាស្លាប់បាត់ព្រោះរោគខ្យល់ទៅហើយ គេបានអង្វរខ្ញុំឱ្យផ្គុងផ្តើម ខ្ញុំក៏យកមកទុកដោយសារយើងគ្មានកូនប្រុស!»

ជាលើកដំបូងដែលតុបបានឃើញអ្នកអន្ទីលើកដៃមកដាក់លើក្បាលរបស់គេ ដូចជាខ្លួនផ្តើមមានម្តាយម្នាក់ដែរ។ គាត់បានបញ្ជាហៅ មនុស្សស្រីចំណាស់ធាត់ខ្មៅម្នាក់ឈ្មោះម៉ែន ឱ្យយកអំបុកនិងស្ករមកឱ្យតុប។ គេហូបដោយអង្គុយនៅនឹងជណ្តើរឡើងខាងត្បូងសំយ៉ាប។ ហូបរបស់ទាំងនេះពិតមែន ប៉ុន្តែសម្គាល់មើលគ្រប់យ៉ាង ឃើញថា ភាពស្រពោន នៃអ្នកអន្ទីទំនងគាត់ឈឺថ្កាត់ជាការពិត។ មនុស្សស្រីម្ចាស់ផ្ទះម្នាក់នេះ មានរូបសម្រស់ផូរផង់សមជាកុលស្ត្រីនៃផ្ទះចាងហ្វាង គួរតែសប្បាយចិត្តតាមដែលបានស្វាមីវិលមកវិញ ស្រាប់តែតុបឃើញគាត់ធ្វើមុខឈឺចាប់មិនរីករាយ ខ្សឹបខ្សៀររៀបរាប់អ្វីម្យ៉ាង ទៅប្តីពេលពីរនាក់គាត់អង្គុយនៅខ្ទះកណ្តាលសួន។

ដោយសរសេរចូលជិត តុមស្តាប់ឮដូច្នេះថា....

«ប្រហែលសុបិននោះប្រាប់មុនពីការពិតហើយ!  ឯយើងមិនព្រមធ្វើតាម បានជាមានទុក្ខដូច្នេះ!»

«កុំទាន់គិតរឿងអីជ្រៅដល់ថ្នាក់ហ្នឹងពេក! ទៅក្នុងផ្ទះសិនចាំនិយាយ!»

ផ្ទះនេះមានមនុស្ស៩នាក់រស់នៅ គឺគូស្វាមីភរិយាគាត់និងកូនស្រីទាំងពីរ អ្នកដាំបាយឈ្មោះម៉ែន ពូបរទេះឈ្មោះមាំជាកូនយាយម៉ែន និងបីនាក់ទៀតជាអ្នកធ្វើស្រែតុមមិនចាំឈ្មោះឡើយព្រោះមិនសូវបានឃើញពួកគេ។ មុនពេលរំសាយទាសករ ឮសូរមកថាគ្រួសារនេះមានមនុស្សជាង៣០នាក់មករស់នៅបម្រើពីក្នុងដល់ក្រៅ។

ចំណែកអ្នកអន្ទីវិញ គាត់តែងតែមានជំងឺរើរវាយនៅពេលចុងក្រោយនេះ ដូច្នេះហើយប្តីរបស់គាត់បានបោះបង់ចោលការងារនៅភ្នំពេញដែលកំពុងត្រូវការគាត់យ៉ាងខ្លាំងដោយសារស្ថានភាពស្រុកទេសមកមើលភរិយានៅផ្ទះ ។

យប់ដំបូងដែលតុមបានទៅដល់ ក៏ជាយប់ដែលស្ត្រីនោះបាត់ខ្លួនផ្អើលឆោឡោអ្នកផ្ទះទាំងពាក់កណ្តាលអធ្រាត្រ។

អ្នកនៅក្នុងផ្ទះទាំងអស់បានរូតអំពាវនាវអ្នកភូមិជួយស្វះស្វែងរកអ្នកអន្ទីគ្រប់ទីកន្លែង។  មិនយូរប៉ុន្មានពួកគេបានរកឃើញគាត់ទៅអង្គុយម្នាក់ឯង នៅប៉ប្រះនឹងទឹកបឹង ក្រោមដើមទេរមួយដែលល្បីថា មានពស់អសិរពិសច្រើនសម្បុក និងពេញដោយសត្វឱម៉ាល់ទុំនៅ។

ធម្មតា ទីនោះសូម្បីតែពេលថ្ងៃក៏គ្មានមនុស្សចាស់ណាហ៊ានទៅដែរ តុមគ្រាន់តែឮវិញ ក៏រួញខ្លាចខ្លាំងភ្នែកនៅកញ្ជើងក នឹកឆ្ងល់មិនដាច់ថា អ្នកអន្ទីទៅអង្គុយទម្លាក់សក់ម្នាក់ឯងសម្លឹងផ្ទៃទឹកយោគជើងស្រងេះស្រងោចមានន័យយ៉ាងណា?

ចាងហ្វាងហែមដឹងថា អ្វីដែលអ្នកផ្ទះបានសរសេរសំបុត្រទៅគឺជាការពិតនៅពេលនេះ។ ភរិយារបស់គាត់ធ្លាប់មិនធ្លាប់ជួបបញ្ហាបែបនេះទេពីមុនមកសោះ ប៉ុន្តែរយៈមួយខែចុងក្រោយ អ្នកអន្ទីចាប់ផ្តើមប្លែក ដោយឧស្សាហ៍ឃើញរបស់ដែលគ្មានរូបរាងពិត ស្រមៃរឿងមិនបានកើតឡើងនិងស្រែកឆោឡោ ដួលសន្លប់។ល។

ព្រោះសេចក្តីស្រឡាញ់លើសលប់ចំពោះភរិយា គាត់បានចោលការងារត្រលប់មកផ្ទះតាមដានរឿងនេះ។ ក្រោយពីបានអ្នកភូមិទៅយកអ្នកអន្ទីបណ្តើរមកផ្ទះហើយ ចាងហ្វាងបានសម្រេចចិត្តចាក់សោរពីក្រៅទុកភរិយាក្នុងបន្ទប់ព្រមទាំងអង្គុយពិគ្រោះកណ្តាលស្បៃរាត្រីកាល ជាមួយនឹងមិត្តភក្តិស្និទ្ធនៅក្នុងភូមិជាមេឃុំក្នុងវ័យស្របាល។

គាត់ឈ្មោះថាមេឃុំឌីម។

«យើងមិនអាចរង់ចាំយូរទេ! គួរតែទៅទាំងយប់!» នេះគឺមេឃុំឌីមបានផ្តល់យោបល់ឱ្យចាងហ្វាងហែមនាំភរិយាឡើង ទៅរកលោកតាម្នាក់ឈ្មោះរង់រស់ទៅចម្ងាយច្រើនគីឡូគួរដែរពីស្រុកនេះ។

«ចាំព្រឹកឬក៏យ៉ាងម៉េច? អន្ទីទើបនឹងសម្រាន្តលក់!»

«ខ្ញុំមិនចង់ឱ្យល្បងហែមចាំទៀតទេពីព្រោះបើនៅតែអ៊ីចឹងអ្នកអាចនឹងធ្វើអ្វីធ្ងន់ធ្ងរលើសដើម!»

ពួកគេបានសម្រេចចិត្តកោះហៅបាវក្រោកមកបរទេះសេះដែលខ្ចីបានពីផ្ទះមន្ត្រី។ ជំនិះនេះ ជាទ្រព្យសម្បត្តិមិនមានក្នុងចំណោមឃ្លាំងដ៏ច្រើននៃគេហដ្ឋាននេះ ។

ការដាក់អ្នកអន្ទីឱ្យសម្រាន្តលើរទេះដែលមានដំបូលចំហជញ្ជាំង មើលពីក្នុងបន្ទប់ទៅដូចជាគាត់កំពុងតែឈឺធ្ងន់ពិតមែន។

«អាតុមម្តាយឯងឈឺ ឯងកូនប្រុសត្រូវទៅតាមបម្រើ!»

ម្ល៉ោះហើយតុមក៏ទៅអង្គុយក្បែរអ្នកនោះ ក្រោយខ្នងអ្នកបរទេះពូមាំ ធ្វើដំណើរទាំងយប់ទៅកាន់ភូមិផ្សេងចម្ងាយប្រហែលជា៥គីឡូម៉ែត្រពីកន្លែងនេះ។  មេឃុំនិងចាងហ្វាងជិះលើរទេះគោ។

ពេលតុមបើកភ្នែកដឹងខ្លួនពីងោកមួយភាំង រទេះបានទៅដល់ផ្ទះលោកតារង់នៅពេលរំលងអធ្រាត្រ។

លោកតារង់គឺជាអ្នកប្រកបរបរមើលជំងឺតាមផ្លូវងងឹតនិងដោះអំពើផ្សេងៗយ៉ាងល្បីល្បាញកាលពីសម័យកាលនោះ ប៉ុន្តែអ្វីៗដូចជាព្រហ្មលិខិត លោកតាកំពុងតែឈឺធ្ងន់ពេកទៅហើយមិនអាចទទួលភ្ញៀវបានទេ ។

នៅពេលទៅដល់ ក្រៅពីមកមិនត្រូវពេល ថែមទាំងគ្មានសង្ឃឹមថានឹងអាចដោះជំងឺបានផងព្រោះត្រូវប្រពន្ធនិងកូនៗរបស់គាត់បណ្តេញឱ្យចេញវិញភ្លាមមិនមានពេលរាក់ទាក់។

ទោះយ៉ាងណា រទេះកំពុងបង្វិលកង់ដោយស្រងេះស្រងោចស្រាប់តែ កូនស្រីច្បងវ័យចំណាស់នៃលោកតាវង់ដែលកំពុងនៅកំដរឪពុកឈឺខាងលើផ្ទះកន្តាំង ស្រែកសួរមកថា៖

«អឺអ្នក! អ្នកជំងឺកើតឆ្នាំអីខែអីឈ្មោះអី?ពុកខ្ញុំគាត់ឱ្យសួរ!»

ចាងហ្វាងក៏បង្អង់ដំណើរនិងពោលប្រាប់គ្រប់ព័ត៌មាន។ ស្ត្រីនោះបង្គាប់ឱ្យរង់ចាំសិន ទម្រាំមានក្មេងៗជំទង់ម្នាក់ជាកូនសិស្សតាវង់ រត់លែងខ្លួនទទេស្លៀកតែក្បិនមកដល់ ហៅរកចាងហ្វាង។ គេបានដាក់សីមាមួយខ្សែមកលើដៃគាត់ហើយគាត់មើលវាដោយមីងមាំង។

គាប់ជួនពេលនោះ គ្រប់គ្នាបានឮសំឡេងមនុស្សចាស់ម្នាក់ក្អកខេះៗនិយាយខ្សោយៗដូចជាចង្កៀងកំពុងរីងប្រេងម្តងលោតភ្លឺ ម្តងអឹរប្រុងរលត់ តែគាត់ខំផ្តល់ដំបូន្មានមកពីលើផ្ទះថា ៖

« ខ្ញុំមិនអាចមើលជំទាវបាន! ប៉ុន្តែខ្ញុំដឹងពីរឿងរបស់គាត់! ចូរឧត្តមមន្ត្រីឆាប់រកគ្រូដែលគេពូកែៗនៅស្រុកផ្សេងឱ្យមកជួយដោះអំពើលើខ្លួនរបស់គាត់មុនដាច់អស្សុជនេះ! ចំណែកខ្សែពណ៌លឿងនេះយកទៅតែកុំចងដៃ ត្រូវចងលើរូបថតគាត់ពន្យាពេលការពារសិន!»

ចាងហ្វាងគ្មានអ្វីក្រៅពីសំពះអរគុណគ្រួសារគ្រូវង្ស ហើយបណ្តើរមេឃុំឱមត្រលប់មករករទេះសេះដោយក្តាប់អំណោយអំបោះសីមាពេញក្នុងដៃ។

រទេះបានវិលត្រលប់ដល់គេហដ្ឋាននៅថ្ងៃដដែល ជាវេលាថ្ងៃត្រង់។

បងស្រីធំរបស់ចាងហ្វាងហែម ឈ្មោះអ្នកគឹមហួនបានមកដល់ពីស្រុកខាងជើង។ ការងាររបស់គាត់គឺមកជួយមើលថែផ្ទះជំនួសប្រពន្ធចាងហ្វាងដែលត្រូវជាប់ក្នុងខ្សែចំណងព្រោះខ្លាចរត់ទៅណាទៀត។ ទោះយ៉ាងណា កូនៗស្រីពីរនាក់ នៅតែរត់លេងចែកផ្លូវគ្នាឆ្វេងស្តាំ ។

«អាគុម! ឯងត្រូវមើលប្អូនណា!អ៊ំៗរវល់ បើឯងមិនមើលប្អូនត្រឹមត្រូវទេ ប្រយ័ត្នបាត់ប្អូនឯងត្រូវរំពាត់ឡើងខ្នងហើយ!»

ក្រៅពីជាប់មើលកូនៗទាំងពីររបស់គាត់គុមមានជាប់នូវមុខការងារមួយចំនួនទៀត ដែលចាងហ្វាងក៏បានប្រគល់ឱ្យធ្វើដូចជា ការសិក្សាភាសាបាលីនិងសិក្សាភាសាបារាំង ប៉ុន្តែគុមនៅតែតាមដានដោយការជក់ចិត្តពីរឿងក្នុងផ្ទះចាងហ្វាង ចង់ដឹងថាអ្វីទៅជាជំងឺរបស់អ្នកអន្ទីដែលជាស្ត្រីដ៏មានចិត្តល្អចំពោះគេ ។

«រូបនេះគឺជារូបគំនូរ ! ពីមុន មាននិស្សិតម្នាក់មកពីស្រុកចិន គេអត់លុយរកស៊ីបានខំគូរឱ្យនិងយកតម្លៃត្រឹមតែ៦រៀល គួរឱ្យភរិយាខ្ញុំតាំងពីនាងទើបនឹងរៀបការមកដល់! »

ឪមសម្លឹងអំបោះនឹងរូបថតៈ

« ប៉ុន្តែខ្សែអំបោះនេះដូចជា តូចនិងខ្លីផងឱ្យចងម៉េចទៅ!»

ម្ល៉ោះហើយ មេឃុំឪម និងភរិយារបស់គាត់ដែលមិនស្គាល់ឈ្មោះ បានរើរក អំបោះផ្សេងៗមកចងបន្តកន្ទុយសងខាងនៃសីមាលឿងរបស់លោកតាវង់។ បានស្រេចកាលណាក៏ចាត់ការព័ទ្ធចងជាបួនផ្នែកជុំវិញរូបគំនូររបស់អ្នកអន្ទីតែម្តង។

ជំងឺហាក់បានជាបាត់ដូចគេបេះនៅថ្ងៃបន្ទាប់ ។

ព្រឹកកាលណាទើបតែក្រោកមកលោត មឹកឈូសថ្មមិនទាន់បានពីរកាំស្រួលបួលផង គុមស្រាប់តែឮអ្នកអង្គុយស្រែកហៅ។

«បើឯងអាល័យលោតមឹក មិនទៅផ្ទះបាយឥឡូវនេះទេ អន្សមចេករបស់ យាយម៉ៅឯងមិនបានស៊ីនោះទេ»

គុមសប្បាយចិត្តរឿងអន្សមមួយហើយ ប៉ុន្តែរឹតតែសប្បាយចិត្តនឹងរឿងរបស់អ្នកអន្ទីដែលញញឹមប្រិមប្រិយ ទម្លាក់សក់ស្រីស្រយ៉ាកស្អាតផូរផង់ដូចកាលពីយប់មិញនេះ មិនបានមានរឿងអ្វីកើតឡើងសោះ។

គេរត់ទៅសុំអន្សមហូប និងលបបានឮពួកអ្នកដែលធ្វើការផ្ទះបាយនិយាយគ្នាផងថា តាចង់ពិតជាគ្រូទេវតា ប៉ុន្តែគាត់បានស្លាប់បាត់ទៅហើយកាលពីយប់មិញ។

មុនពេលគាត់ស្លាប់គាត់ចេះឆ្លៀតបានជួយអ្នកអន្ទីទៀត?

មេឃុំឪមចេះនាំចាងហ្វាងនេះ ទៅដោះជំងឺប្រពន្ធទាន់ នឹងទទួលបានសីមាអំបោះពណ៌លឿងដែលជារបស់ស័ក្តិសិទ្ធតាវង់មិនងាយប្រគល់ឱ្យអ្នកណានោះទេលើកលែងតែគាត់យល់ថា ជាអ្នកជំងឺធ្ងន់ធ្ងរ។

តាមពិតមានពេទ្យបារាំងមកដល់ច្រើនហើយនៅស្រុកខ្មែរប៉ុន្តែគ្រប់គ្នាជឿថារឿងនេះមិនមែនសុខភាពធម្មតាដែលអាចព្យាបាលដោយថ្នាំកើតឡើយ តែមកពីអ្វី? អំពើរបស់អ្នកណា? ម្តេចដាក់មកលើអ្នកអន្ទីដែលជាមនុស្សល្អម្នាក់សម្រាប់គុម?

មិនមានចម្លើយសម្រាប់រឿងនេះទេ ប៉ុន្តែតុមតែងតែលបស្តាប់ចង់ដឹងនូវអ្វីៗដែលមេឃុំឪមនិយាយគ្នាជាមួយនិងចាងហ្វាងហែម។

រឿងដែលគេត្រូវចងចាំខ្ជាប់គឺសីមាអំបោះលឿងមិនឱ្យរបូតចេញដាច់ខាត។

«អ៊ំស្រី! តើអ្នកអ៊ំស្រីនឹងនៅកន្លែងនេះទៀតជួយមើលមីអូនរត្ន័ឬមួយក៏ត្រលប់ទៅភូមិវិញ?!»

តុមសួរអ៊ុំគីមហួនជាបងស្រីបង្កើតនៃចាងហ្វាង។

ជាមួយនឹងទឹកមុខ ស្លូត ស្ត្រីនេះជាអ្នកមេម៉ាយក្មេងនិងមិនមានកូន។ គាត់ស្លៀកតែក្បិនស្រគាំនិងអាវទេសឯកសដៃវែង កាន់ទុក្ខប្តីស្លាប់ពីរបីឆ្នាំមកហើយ។

គាត់ជាកូនគ្រួសារអ្នកថ្លៃថ្នូរ ជាបងស្រីបង្កើតរបស់ចាងហ្វាងហែមដែលគាត់មកនេះ ព្រោះជួយមើលការងារផ្ទះ។

«ឬក៏ឯងមិនចង់ឱ្យអ៊ុំនៅអាតុម?!»

«ទេ បានអ្នកនៅល្អណាស់! ខ្ញុំនឹងបានមិនសូវនឿយចំពោះកុលាបរ័ត្ន!»

«កុំត្អូញត្អែរ! ជាកូនប្រុសធំដូចជាឯង គួរមើលប្អូននិងថែពុកម្តាយពេលឯងធំឡើង! ទៅៗសូត្រសាស្ត្រាក្រែងហែមត្រលប់មកពីសាលាជំនុំពេលណាគាត់នឹងប្រើសូត្រ ក្រែងតែមិនចាំមិនចេះ ត្រូវរំពាត់បាន!»

តែចាងហ្វាងតាមពិតមិនដែលវាយឬដាក់ទណ្ឌកម្មតុមទេ។ ម៉្យាងព្រឹកនេះភរិយាលោកបានស្រស់បស់វិញទៀត គ្រប់យ៉ាងនឹងប្រសើរ ។

ទោះបីយ៉ាងណា តុមកត់សម្គាល់ឃើញថាទឹកមុខរបស់អ៊ំ គឹមហួន ស្រពោនចម្លែក។

« បងដឹងថា មានអ្នកណាម្នាក់បានដាក់អំពើអាគមអូមអាមលើអន្ទី បងយកស្ករនេះមកតាមទម្លាប់អ្នកស្រុកយើង គេធ្វើឡើងពីទឹកត្នោតនិងផ្កាផ្កា វាជាគ្រឿងនាំមកនូវសិរីមង្គលប្អូន លេបសិនទៅ!»

អ្នកស្រីចាងហ្វាងបានទទួលយកស្ករពីបងស្រីថ្លៃហើយដាក់ខាំលេបចូលក្នុងមាត់។

អ្នកអន្ទី គឺជាមនុស្សដែលគប្បីទទួលបានការស្រឡាញ់ពីគេឯងគ្រប់គ្នាព្រោះគាត់ជាស្ត្រីមានសម្រស់ មានចរិតទន់ភ្លន់ និងមានសន្តានចិត្ត។ ប៉ុន្តែថ្ងៃមួយតុមបានដឹងមកថា គាត់មិនចេះអក្សរនោះទេ មិនថាបារាំង ឬខ្មែរ។

កាលពីគាត់នៅក្មេង ស្រុកកើតកលិយុគ គ្រួសាររបស់គាត់មិនសូវបាននៅមួយកន្លែង អាស្រ័យរស់ដោយការរត់ចុះឡើង។ ឪពុកគាត់ដោយសារតែជំពាក់ប្រាក់នាម៉ឺនធ្វើចម្ការខាតបង់លង់លិច ហើយ

រកអ្វីដោះបំណុលមិនបានក៏ត្រូវគេទាមទារយកកូនស្រីទៅធ្វើជាទាសករ។ ប៉ុន្តែឪពុកម្ដាយមិនដាច់ចិត្តក៏នាំកូនស្រី រត់ពួនចុះឡើងៗ រហូតដល់ពេលធំពេញវ័យក៏ត្រូវជាគូនឹងលោកចាងហ្វាង។ គុមយល់ថា គាត់ពិតជាស្រ្តីមានសំណាងដែលមិនចេះអក្សរប៉ុន្តែមានប្តីថ្នាក់ថ្នម មានអ្នកបម្រើទាំងអស់យកចិត្តទុកដាក់ ។

តាមដឹងមក ឪពុកម្ដាយរបស់ចាងហ្វាងហែមនិងឪពុកម្ដាយរបស់គាត់ធ្លាប់មានជំពាក់វាក់វិនសម្តីគ្នា ឬក៏ជំពាក់គុណគ្នាអ្វីកាលពីក្មេងៗ ដែលធ្វើឱ្យកូនប្រុសស្រីទាំងពីរត្រូវភ្ជាប់ពាក្យជាមួយគ្នា ដូច្នេះហើយបានជា អ្នកអន្ទីមិនអាចទៅធ្វើការដោះបំណុលជូនឪពុកបានទេ ដោយសារមានចំណងស្វាមីភរិយាតាំងពីក្មេងៗមក។